# Election Reform Alliance (ERA)

## ការបង្ហាញ និងពិភាក្សា
## ស្តីពី
## របាយការណ៍រួមសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) មានកិត្តិយសសូមជម្រាបជូន និងគោរពអញ្ជើញដល់ លោក លោកស្រី នាងកញ្ញាតំណាង សារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) នឹងរៀបចំការបង្ហាញ និងពិភាក្សាស្តីពី **"របាយការណ៍រួមសម្រាប់ការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាឆ្នាំ២០១៣"**។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) គឺសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងសម្រាប់ការបោះឆ្នោតថ្នាក់ជាតិនៅខែកក្កដា ឆ្នាំ២០១៣ ។ ERA មានអង្គការជាសមាជិកចំនួន២០ដែលមានបំណងជំរុញឲ្យមានការកែលម្អ សម្រាប់ការបោះឆ្នោតនាពេលអនាគត តាមរយៈការបង្រួបបង្រួម និងសម្របសម្រួលឲ្យមានសម្លេងតែមួយ ។ សមាជិករបស់ERA រួមមាន ៖ អង្គការសង្កេតការណ៍បោះឆ្នោត អង្គការយុវជន អង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន អង្គការសិទ្ធិមនុស្ស និងអង្គការដ៏ទៃទៀតជាច្រើន ដែលកំពុងធ្វើការឆ្ពោះទៅរកអានុសាសន៍សម្រាប់ការកែទម្រង់ការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍រួមរបស់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតនឹងចេញផ្សាយជាផ្លូវការនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣។

**ទីកន្លែង៖ សណ្ឋាគារ អ៊ីមភើរៀល ហ្គាដេន** (Imperial Garden Villa and Hotel) Ballroom I
**កាលបរិច្ឆេទ៖ ថ្ងៃសុក្រ ទី១៣ ខែធ្នូ ឆ្នាំ ២០១៣ ពីម៉ោង ៨.០០ ព្រឹក ដល់ ១២.០០ ព្រឹក**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគោរពអញ្ជើញលោក លោកស្រី នាងកញ្ញា អញ្ជើញចូលរួមយកព័ត៌មានតាមការគួរ។

**សូមអរគុណ!**
*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង ០១២ ៦៥ ៤៩ ៥០ ឬ ០១២ ៩៨ ៧៦ ៧៦*